**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០០២/២៥ **ក.ប**/ស.ជ.ណ.ម.ព

# សេចក្តីជូនដំណឹង

## ស្តីពីពិព័រណ៍ការងារអនឡាញ សម្រាប់ប្រព័ន្ធពលករជំនាញនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជន ជាពិសេសអ្នកដែលមានបំណងស្វែងរកការងារធ្វើនៅប្រទេសជប៉ុន ឱ្យបានជ្រាបថា រដ្ឋាភិបាលជប៉ុនគ្រោងនឹងរៀបចំ **ពិព័រណ៍ការងារអនឡាញសម្រាប់ប្រព័ន្ធពលករជំនាញនៅប្រទេសជប៉ុន** តាមរយៈប្រព័ន្ធវីដេអូអនឡាញ Zoom Meeting ដែលនឹងប្រព្រឹត្តទៅចំនួន ៣លើក គឺនៅថ្ងៃទី១៧, ១៨ និង៣១ ខែមករា ឆ្នាំ២០២៥។ កម្មវិធីនេះ នឹងមានការពន្យល់លម្អិតពីប្រព័ន្ធពលករជំនាញនៅប្រទេសជប៉ុន និងការណែនាំពីក្រុមហ៊ុនទទួល និងសមាគមគាំទ្រនៅក្នុងប្រទេសជប៉ុន។

លោកអ្នកអាចចុះឈ្មោះចូលរួមពិព័រណ៍ការងារអនឡាញនេះដោយឥតគិតថ្លៃ ដោយស្កេន QR Code ខាងក្រោម ដើម្បីចុះឈ្មោះ និងឆ្លើយសំណួរចាំបាច់ អំពីឈ្មោះ សញ្ជាតិ ប្រទេសដែលកំពុងស្នាក់នៅ ប្រភេទការងារដែលចាប់អារម្មណ៍ អ៊ីម៉ែល កម្រិតភាសាជប៉ុន និងស្ថានភាពការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ សាធារណជន និងកម្មសិក្សាការីបច្ចេកទេសបញ្ចប់កម្មសិក្សានៅប្រទេសជប៉ុន ដែលមានបំណងចូលរួមពិព័រណ៍ការងារអនឡាញនេះ ជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

(QR Code សម្រាប់ចុះឈ្មោះ)

**ចម្លងជូន៖**

- សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)
- គ្រប់ទីភ្នាក់ងារជ្រើសរើសឯកជន
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ